**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ...០០៥.....សហវ.......

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការកែសម្រួលមូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុកក្រៅពីបារីនិងស្រា

យោងតាមប្រការ ១ នៃប្រកាសលេខ ១៣៩ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការអនុវត្តឱ្យមានភាពទន់ភ្លន់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំការអនុវត្តមូលដ្ឋានគិតអាករពិសេសលើមុខទំនិញដែលផលិតក្នុងស្រុកក្រៅពីបារីនិងស្រា ដូចជា÷ ស្រាបៀរ ភេសជ្ជៈគ្មានជាតិសុរា និងមុខទំនិញជាប់អាករពិសេសដទៃទៀត ត្រូវបានកំណត់ស្មើនឹង ៩០ ភាគរយ នៃថ្លៃផ្គត់ផ្គង់កត់ត្រាក្នុងវិក្កយបត្រឱ្យទៅអតិថិជន ដោយមិនរួមបញ្ចូល÷

- អាករលើតម្លៃបន្ថែម និងអាករពិសេសខ្លួនឯង សម្រាប់អ្នកជាប់ពន្ធក្នុងរបបស្វ័យប្រកាស (របបពិត)
- អាករលើផលរបរ និងអាករពិសេសខ្លួនឯង សម្រាប់អ្នកជាប់ពន្ធក្នុងរបបម៉ៅការ។

មូលដ្ឋានគិតអាករពិសេសថ្មីនេះនឹងត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៥ តទៅ។

អាស្រ័យហេតុនេះ សូមលោក-លោកស្រីជានាយកសហគ្រាសផលិតទំនិញជាប់អាករពិសេសក្នុងស្រុកទាំងអស់ជ្រាប និងអនុវត្តឱ្យបានត្រឹមត្រូវប្រកបដោយប្រសិទ្ធភាពខ្ពស់។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

Collection by VCAT Professional Consultant

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798